# តើការលេងល្បែងស៊ីសងពិតជាធ្វើឱ្យអ្នកខាតបង់អស់ប៉ុន្មាន?



1G (1)។ 1220។ LG21100

## ច្រើនជាងការគិតរបស់អ្នកទៀត។

GambleAware
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

# តើការលេងល្បែងស៊ីសងពិតជាធ្វើឱ្យអ្នកខាតបង់អស់ប៉ុន្មាន?



1G (4)។ 1220។ LG21400

## ច្រើនជាងការគិតរបស់អ្នកទៀត។

GambleAware
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

3G១ 1220១ LG23100

# មួយក្នុងចំណោម មួយលាន។

នោះគឺជាឱកាសដែលអ្នកត្រូវ
រង្វាន់ធំនៅលើម៉ាស៊ីនលេងល្បែងស៊ីសងមួយ។

GambleAware
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

# ត្រូវការសម្រាកពីការលេងល្បែងស៊ីសង?




**អ្នកអាចហាមឃាត់ខ្លួនឯងពីការលេងល្បែងស៊ីសងនៅទីនេះ។ សូមនិយាយជាមួយអ្នកគ្រប់គ្រងល្បែង ឬហៅទូរសព្ទទៅ GambleAware តាមរយៈលេខ 1800 858 858។**

**GambleAware**
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

# ជំនួយនៅជិតបង្កើយ




## នៅទីនេះសម្រាប់អ្នក 24ម៉ោងក្នុងមួយសប្តាហ៍។

GambleAware
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

# ជំនួយនៅជិតបង្កើយ




## នៅទីនេះសម្រាប់អ្នក 24ម៉ោងក្នុងមួយសប្តាហ៍។

**GambleAware**
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

បើសិនអ្នកចង់និយាយជាមួយនរណាម្នាក់នៅថ្ងៃនេះដើម្បីស្វែងរកព័ត៌មាន និងការគាំទ្រ សូមហៅទូរសព្ទទៅ

**GambleAware**
gambleaware.nsw.gov.au
1800 858 858

GambleAware នៅបម្រើអ្នកគ្រប់ពេល 24ម៉ោងក្នុងមួយថ្ងៃ 365ថ្ងៃក្នុងមួយឆ្នាំ។

អ្នកអាចរកជំនួយដោយសម្ងាត់ និងមិនគិតថ្លៃ។

អ្នកអាចនិយាយជាមួយនរណាម្នាក់ជាភាសារបស់អ្នកបាន។ យើងមានអ្នកផ្តល់ប្រឹក្សាដែលនិយាយភាសាផ្សេងពីភាសាអង់គ្លេស ហើយអ្នកបកប្រែផ្ទាល់មាត់សម្រាប់ជួយអ្នក។

យើងផ្តល់ការគាំទ្រដល់អ្នកលេងល្បែងស៊ីសង – ហើយនិងក្រុមគ្រួសារ ព្រមទាំងមិត្តភក្តិរបស់ពួកគេ។

បោះពុម្ពដោយ
The Office of Responsible Gambling
GPO Box 7060, Sydney NSW 2001

www.responsiblegambling.nsw.gov.au

សម្រាប់ច្បាប់ចម្លងជាច្រើនច្បាប់នៃបណ្ណព័ត៌មាននេះ៖
អ៊ីម៉េល៖ contact.us@liquorandgaming.nsw.gov.au
ទូរសព្ទ៖ 1300 024 720

NSW GOVERNMENT

ខែវិច្ឆិកា ឆ្នាំ 2020 | ភាសាអង់គ្លេស

# ព័ត៌មានអំពីក្តីសង្ឃឹម

## ភ្នាល់នៅលើម៉ាស៊ីនលេងល្បែងស៊ីសង?



**GambleAware**
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

អ្នកអាចលេងល្បែងចុចម៉ាស៊ីនផូកឃី (pokies) រយៈពេលឆាប់ ឬក៏យូរ ប៉ុន្តែតើអ្នកពិតជាយល់ដឹង អំពីម៉ាស៊ីនទាំងនេះកម្រិតណា ហើយតើម៉ាស៊ីនទាំងនេះដំណើរការយ៉ាងដូចម្តេច?

ម៉ាស៊ីនផូកឃ័រ គឺរចនាឡើងដើម្បីទាញប្រាក់ចំណេញសម្រាប់កន្លែងដែលមានអាជ្ញាបណ្ណសម្រាប់ដំណើរការម៉ាស៊ីនទាំងនេះ។ នៅរដ្ឋញូសៅវ៉េល កន្លែងទាំងនោះគឺ សណ្ឋាគារ ក្លឹបដែលបានចុះបញ្ជី និង កាស៊ីណូ។ ខណៈដែលម៉ាស៊ីនផូកឃ័រអាចជាវិធីកំសាន្តសប្បាយមួយដើម្បីចាយលុយ ម៉ាស៊ីនទាំងនេះមិនបង្កើតឡើងដើម្បីជួយមនុស្សឱ្យរកលុយនោះទេ។ ទោះជាអ្នកអាចឈ្នះលុយខ្លះក្នុងរយៈពេលខ្លីក្តី តែក្នុងរយៈពេលវែង វាស្ទើរតែមិនអាចឈ្នះប្រាក់បានទេ។





## តើអ្វីទៅជាល្បែងឱកាស?

ម៉ាស៊ីនលេងល្បែងស៊ីសងគឺជាល្បែងឱកាស។ ទោះជាអ្នកឈ្នះ ឬចាញ់គឺជាសំណាងទាំងស្រុង។

នៅក្នុងល្បែងឱកាសគឺគ្មានយុទ្ធសាស្ត្រក្នុងការលេង ឬគំរូ ដែលអាចមានឥទ្ធិពលទៅលើ ថាតើអ្នកឈ្នះ ឬចាញ់នោះទេ។ ម៉ាស៊ីនលេងល្បែងស៊ីសងមានកម្មវិធីកុំព្យូទ័រដែលគេស្គាល់ថាជាម៉ាស៊ីនជ្រើសលេខដោយចៃដន្យ។

នៅពេលអ្នកចុចប៊ូតុងលេងល្បែងម្តងៗ កម្មវិធីកុំព្យូទ័រជ្រើសទីតាំងនៃរូបសញ្ញា ឬរូបភាពនីមួយៗដោយចៃដន្យ។

រដ្ឋាភិបាលរដ្ឋញូសៅវ៉េលត្រួតពិនិត្យ កម្មវិធីប្រតិបត្តិការសម្រាប់ម៉ាស៊ីនលេងល្បែងទាំងអស់ ដើម្បីធានាថាម៉ាស៊ីនទាំងនេះ ឆ្លើយតបទៅតាមស្តង់ដារបច្ចេកទេសយ៉ាងតឹងរឹង។ វាជាអំពើផ្ទុយនឹងច្បាប់សម្រាប់នរណាម្នាក់ដែលកែម៉ាស៊ីន ឬផ្លាស់ប្តូរប្រតិបត្តិការនៃម៉ាស៊ីនលេងល្បែងស៊ីសងមួយដោយគ្មានការអនុញ្ញាត។

ម៉ាស៊ីនលេងល្បែងមិនអាចគិត ឬចងចាំបានទេ។ ម៉ាស៊ីនទាំងនេះបញ្ជាដោយកម្មវិធីកុំព្យូទ័រដែលផ្តល់លទ្ធផលដោយចៃដន្យ។

## តើម៉ាស៊ីនលេងល្បែងស៊ីសងដំណើរការដូចម្តេច?

ម៉ាស៊ីនលេងល្បែងមានផែនដែលបង្ហាញរូបសញ្ញា ឬរូបភាព។ រូបសញ្ញាដែលកំណត់ឱ្យឈប់នៅទីតាំងនីមួយៗ នៅលើផែននីមួយៗ ត្រូវបានដាក់កម្មវិធីចូលនៅក្នុងម៉ាស៊ីននោះ។ ទីតាំងទាំងនេះគឺមានលក្ខណៈអចិន្ត្រៃយ៍ ហើយមិនផ្លាស់ប្តូរពីហ្គេមមួយ ទៅហ្គេមមួយទៀតទេ។ ទីតាំងផ្សេងទៀតនៅលើផែនមានរូបសញ្ញាផ្សេងទៀតដែលកំណត់ជាអចិន្ត្រៃយ៍។

ជម្រើសដោយចៃដន្យនៃទីតាំងគឺធ្វើឡើងដាច់ដោយឡែក និងឯករាជ្យសម្រាប់ផែននីមួយៗ។ នៅលើម៉ាស៊ីនមួយមានផែនចំនួនប្រាំ ហើយអាចមានទីតាំងឈប់ចំនួន 35 នៅលើផែននីមួយៗ ដូច្នេះអាចមានបន្សំទីតាំងឈប់ចំនួន 52លាន។

ម៉ាស៊ីនលេងល្បែងនីមួយៗបង្កើតឡើងខុសៗគ្នា ហើយមានក្តីសង្ឃឹមឈ្នះរង្វាន់ធំបំផុតខុសៗគ្នា ប៉ុន្តែជាទូទៅ ឱកាសរបស់អ្នកក្នុងការឈ្នះរង្វាន់ធំគឺមិនច្រើនជាងឱកាសមួយក្នុងមួយលាននោះទេ និងអាចថាទាបជាងនេះ។

ក្នុងរយៈពេលវែង ម៉ាស៊ីននេះបង្កើតឡើងដើម្បីឈ្នះ ហើយអ្នកនឹងចាញ់ប្រាក់។

## តើអ្នកអាចបង្កើនក្តីសង្ឃឹមរបស់អ្នកបានទេ?

មិនបានទេ – កត្តាខាងក្រៅមិនទាក់ទងទៅនឹងលទ្ធផលនៃល្បែងស៊ីសងតាមម៉ាស៊ីននោះទេ ដោយរាប់បញ្ចូលទាំងហ្គេមពីមុនៗមកផងដែរ។

នេះមានន័យថា វាមិនអាចទៅរួចទេក្នុងការទាយពីអាកប្បកិរិយារបស់ម៉ាស៊ីនលេងល្បែងនោះ។ រូបសញ្ញានីមួយៗដែលចេញគឺត្រូវបានជ្រើសដោយចៃដន្យ។

វាមិនមានអ្វីខុសប្លែកទេថាតើ៖

- អ្នកលេងម៉ាស៊ីនភ្លាមបន្ទាប់ពីអ្នកណាម្នាក់ផ្សេងទៀតបានឈ្នះលុយច្រើនពីម៉ាស៊ីននេះ
- អ្នកលេងម៉ាស៊ីនដែលមិនមានអ្នកឈ្នះលុយច្រើន អស់រយៈពេលយូរមកហើយ
- អ្នកលេងនៅពេលណាមួយ នៃពេលថ្ងៃ ឬយប់
- អ្នកលេងនៅថ្ងៃណាខ្លះក្នុងសប្តាហ៍
- អ្នកចុចប៊ូតុងដោយវិធីណាក៏ដោយ។

អ្នកមិនអាចកែលទ្ធផលល្បែងផូកឃីបានទេ។

បើសិនអ្នកចង់និយាយទៅកាន់នរណាម្នាក់នៅថ្ងៃនេះដើម្បីស្វែងរក ព័ត៌មាន និងការគាំទ្រ សូមហៅទូរសព្ទទៅ

**GambleAware**
gambleaware.nsw.gov.au
1800 858 858

GambleAware នៅបម្រើអ្នកគ្រប់ពេល 24ម៉ោងក្នុងមួយថ្ងៃ 365ថ្ងៃ ក្នុងមួយឆ្នាំ។

អ្នកអាចរកជំនួយបានដោយសម្ងាត់ និងមិនគិតថ្លៃ។

អ្នកអាចនិយាយទៅកាន់នរណាម្នាក់ជាភាសារបស់អ្នកបាន។ យើងមាន អ្នកផ្តល់ប្រឹក្សាដែលនិយាយភាសាផ្សេងពីភាសាអង់គ្លេស និងអ្នកបកប្រែ ផ្ទាល់មាត់សម្រាប់ជួយអ្នក។

យើងផ្តល់ការគាំទ្រដល់អ្នកលេងល្បែងស៊ីសង –និងក្រុមគ្រួសារ ព្រមទាំង មិត្តភក្តិរបស់ពួកគេ។

បោះពុម្ពដោយ
The Office of Responsible Gambling
GPO Box 7060, Sydney NSW 2001

www.responsiblegambling.nsw.gov.au

សម្រាប់ច្បាប់ចម្លងជាច្រើនច្បាប់នៃបណ្ណព័ត៌មាននេះ៖
អ៊ីម៉េល៖ contact.us@liquorandgaming.nsw.gov.au
ទូរសព្ទ៖ 1300 024 720

NSW GOVERNMENT

ខែឧសភា ឆ្នាំ 2024 | ភាសាអង់គ្លេស
2-ភាសាអង់គ្លេស។ 0524.LG32100

# ព័ត៌មានអំពីក្តីសង្ឃឹម

## ភ្នាល់ ឡូតូ ចាក់ឆ្នោត ឬ ឃីណូ (Keno)?



**GambleAware**
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

អ្នកប្រហែលជាបានឮអ្នកឈ្នះឡូតូ និងផាវវើបល (Powerball) មានសំណាងឈ្នះឆ្នោត ឬក៏បានត្រូវលេខដែលឈ្នះក្នុងឃីណូ។

ក្ដីសង្ឃឹមនៃការឈ្នះមានភាពខុសគ្នាអាស្រ័យទៅលើល្បែងមួយណាដែលអ្នកលេង និងទៅលើរង្វាន់ផងដែរ។ លេខដែលឈ្នះ និងសន្លឹកឆ្នោតទាំងអស់ត្រូវបានជ្រើសដោយចៃដន្យ។ ដូច្នេះគ្មានវិធីសាស្ត្រក្នុងការលេងដើម្បីបង្កើនឱកាសឈ្នះបាននោះទេ។

# តើអ្នកមានឱកាសប៉ុន្មានក្នុងការឈ្នះឆ្នោត?

## វិនហ្វលថ្ងៃធ្វើការ (Weekday Windfall) និងឡូតូថ្ងៃសៅរ៍ (Saturday Lotto)

ការចេញ Weekday Windfall គឺធ្វើឡើងនៅថ្ងៃចន្ទ ពុធ និងសុក្រ។ ការចេញ Saturday Lotto គឺធ្វើឡើងនៅថ្ងៃសៅរ៍។ នៅក្នុងល្បែងនីមួយៗនៃ Weekday Windfall និង Saturday Lotto មានកូនបាល់ចំនួន 45 ដែលមានលេខពីលេខ 1 ដល់លេខ 45។ លេខចំនួនប្រាំបីត្រូវបានជ្រើសរើសដោយចៃដន្យដោយម៉ាស៊ីន។ កូនបាល់ចំនួនប្រាំមួយដំបូងដែលបានជ្រើសរើសគឺជាលេខឈ្នះ ហើយកូនបាល់ពីរចុងក្រោយគឺជាលេខបន្ថែម។ អ្នកត្រូវលេងយ៉ាងតិចបំផុតបួនហ្គេម។ ឱកាសនៃការឈ្នះរង្វាន់វគ្គទីមួយ (Division One) (ដោយផ្អែកលើល្បែងស្តង់ដារមួយហ្គេម) គឺ 1 ក្នុងចំណោម 8.145.060។

## ល្បែងឡូតូស្រ្ដាយខ៍ (Lotto Strike)

Lotto Strike គឺផ្អែកទៅលើលេខឈ្នះចំនួនបួនលេខដំបូង ចេញពីឡូតូថ្ងៃសៅរ៍ (Saturday Lotto) ឬល្បែងវិនហ្វលថ្ងៃធ្វើការ (Weekday Windfall) ។ អ្នកលេងជ្រើសរើសលេខចំនួនបួនក្នុងចន្លោះពីលេខ 1 ដល់លេខ 45។ ដើម្បីចូលលេង Lotto Strike អ្នកក៏ត្រូវតែលេង Saturday Lotto ឬ Weekday Windfall ផងដែរ។ រង្វាន់តាមវគ្គ (Division) ត្រូវបានប្រគល់ជូនទៅតាមថាតើលេខឈ្នះមានចំនួនប៉ុន្មានលេខ ត្រូវនឹងលេខបួនដំបូងនៃ Saturday Lotto ឬ Weekday Windfall ដែលបានចេញ ក៏ប៉ុន្តែ គឺតែនៅពេលដែលលេខត្រូវបានជ្រើសរើសត្រូវតាមលំដាប់លំដោយត្រឹមត្រូវតែប៉ុណ្ណោះ។ ឱកាសឈ្នះរង្វាន់ Division One (ត្រូវលេខឈ្នះទាំងបួន ដោយផ្អែកលើល្បែងស្តង់ដារមួយហ្គេម) គឺ 1 ក្នុងចំណោម 3.575.880។

## ល្បែងផាវវើបល (Powerball)

ការចេញ Powerball ធ្វើឡើងនៅយប់ថ្ងៃព្រហស្បតិ៍។ លេខ Powerball ត្រូវបានជ្រើសចេញពីម៉ាស៊ីនចំនួនពីរគ្រឿង។ លេខចំនួនប្រាំពីរត្រូវបានជ្រើសចេញពីម៉ាស៊ីនទីមួយ ដោយមានលេខ 1ដល់ 35 និងលេខ Powerball មួយត្រូវបានជ្រើស ចេញពីម៉ាស៊ីនទីពីរ ដោយមានលេខ 1 ដល់ 20។ អ្នកត្រូវលេងយ៉ាងតិចបំផុតបួនហ្គេម។ ឱកាសឈ្នះរង្វាន់ Division One (ដោយផ្អែកលើល្បែងស្តង់ដារមួយហ្គេម) គឺ 1 ក្នុងចំណោម134.490.400។

## ល្បែងឡូតូអូស្ត្រាលី (Oz Lotto)

ការចេញ Oz Lotto គឺធ្វើឡើងនៅយប់ថ្ងៃអង្គារ។ Oz Lotto មានកូនបាល់ចំនួន 47គ្រាប់ ដោយមានលេខពីលេខ 1 ដល់លេខ 47។ លេខចំនួនដប់ត្រូវបានជ្រើសដោយចៃដន្យ។ លេខចំនួនប្រាំពីរដំបូងដែលបានជ្រើសគឺជាលេខឈ្នះ និងលេខបីចុងក្រោយគឺជាលេខបន្ថែម។ អ្នកត្រូវលេងល្បែងយ៉ាងតិចបំផុតមួយហ្គេម។ ឱកាសឈ្នះរង្វាន់ Division One (ដោយផ្អែកលើល្បែងស្តង់ដារមួយហ្គេម) គឺ 1 ក្នុងចំណោម 62.891.499។

## ឆ្នោតឈ្នះភ្លាមៗ (Instant Lotteries) – 'ឆ្នោតកោសភ្លាមៗ'

គេក៏ហៅវាថា ឆ្នោតកោសភ្លាមៗ ឆ្នោតឈ្នះភ្លាមៗពាក់ព័ន្ធនឹងការបង្ហាញលេខសញ្ញា ឬរូបភាពនៅលើសន្លឹកឆ្នោត។ ក្ដីសង្ឃឹមពិតដែលអ្នកនឹងឈ្នះខុសគ្នាទៅតាមប្រភេទល្បែងដែលអ្នកលេង។ ឧទាហរណ៍ ឱកាសឈ្នះរង្វាន់កំពូលនៅលើសន្លឹកឆ្នោតកោសភ្លាមតម្លៃ 2ដុល្លារគឺ 1 ក្នុងចំណោម 1.250.000។

## ឆ្នោតជ្រើសលេខ (Draw Lotteries) – 'ឆ្នោតសំណាង (Lucky Lotteries)'

រង្វាន់ធំបំផុតរបស់ Lucky Lotteries Super Jackpot និងរង្វាន់ធំរបស់ Lucky Lotteries Mega Jackpot មានសន្លឹកឆ្នោតមានលេខ 270.000សន្លឹក និង200.000សន្លឹក តាមលំដាប់។

លេខឈ្នះគឺត្រូវបានជ្រើសដំបូងគេពីធុងសន្លឹកឆ្នោត ហើយរង្វាន់ផ្ដល់ជូនតាមសន្លឹកឆ្នោតដោយមានលេខឈ្នះ និងនៅជុំវិញលេខឈ្នះ។ បន្ទាប់មក លេខរង្វាន់ធំគឺជ្រើសចេញពីធុងសន្លឹកឆ្នោត។

រង្វាន់ធំគឺឈ្នះនៅពេលលេខមួយនៃលេខឈ្នះត្រូវនឹងលេខរង្វាន់ធំ។ ឱកាសឈ្នះរង្វាន់ធំបំផុតរបស់ Lucky Lotteries ស្ថិតក្នុងល្បែងមួយហ្គេមគឺ 1 ក្នុងចំណោម 18.385.877និង ឱកាសឈ្នះរង្វាន់ធំរបស់ Lucky Lotteries ស្ថិតក្នុងល្បែងមួយគឺ 1 ក្នុងចំណោម 9.483.168។

## ឆ្នោតបង់ប្រាក់ជាបន្តបន្ទាប់ – 'Set for Life'

ឈុតសន្លឹកឆ្នោត Set for Life គឺលេងក្នុងរយៈពេលប្រាំពីរថ្ងៃជាប់ៗគ្នា ហើយអ្នកត្រូវលេងយ៉ាងហោចណាស់ ចំនួនពីរហ្គេមក្នុងពេលតែមួយ។ នៅក្នុង Set for Life លេខចំនួនប្រាំបួនត្រូវបានជ្រើសដោយចៃដន្យពីឈុតលេខចំនួន 44 ដោយមានលេខពី 1 ដល់ 44។ លេខចំនួនប្រាំពីរដែលបានជ្រើសដំបូងជាលេខឈ្នះ ហើយលេខពីរចុងក្រោយគឺជាលេខបន្ថែម។ ឱកាសនៃការត្រូវលេខចំនួនប្រាំពីរទាំងអស់ និងរង្វាន់ឈ្នះវគ្គទីមួយ នៅក្នុងការលេងល្បែងមួយហ្គេមគឺ 1 ក្នុងចំណោម 38.320.568។

## ល្បែងឃីណូ (Keno)

នៅក្នុងល្បែងនីមួយរបស់ Keno មានលេខចំនួន 20 ត្រូវបានជ្រើសដោយចៃដន្យពីលេខចំនួន 80 ហើយរង្វាន់គឺផ្អែកទៅលើចំនួនលេខដែលអ្នកបានជ្រើស ត្រូវគ្នានឹងលេខដែលបានជ្រើសដោយម៉ាស៊ីន។ អ្នកលេងអាចជ្រើសលេខ 1-10, 15, 20 ឬ40 ក្នុងល្បែងនីមួយៗ។ បើសិនអ្នកជ្រើសលេងលេខ 7, 8, 9 ឬ 10 មួយភាគនៃការភ្នាល់របស់អ្នកនឹងត្រូវបន្ថែមទៅក្រុមរង្វាន់ធំដែលបន្ទាប់មកអ្នកនឹងមានឱកាសឈ្នះ។ ក្ដីសង្ឃឹមពិតដែលអ្នកនឹងឈ្នះរង្វាន់គឺខុសៗគ្នាអាស្រ័យទៅលើចំនួនលេខដែលអ្នកជ្រើសលេង។ ឧទាហរណ៍ ឱកាសឈ្នះរង្វាន់ធំ ចំនួន 10លេខ គឺ 1 ក្នុងចំណោម 8.911.711។

Keno មានលេងនៅក្នុងក្លឹប សណ្ឋាគារ និងកាស៊ីណូជាច្រើន។

# តើអ្នកអាចបង្កើនក្ដីសង្ឃឹមនៅក្នុងការចាក់លេខឆ្នោត ឬ Keno បានទេ?

មិនបានទេ – ពីព្រោះលេខឈ្នះត្រូវបានជ្រើសដោយចៃដន្យ ឈុតលេខណាក៏ដោយមានឱកាសឈ្នះដូចគ្នាបេះបិទទៅនឹងឈុតលេខផ្សេងទៀត។ ល្បែងនានាគឺត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលរដ្ឋញូសៅវ៉េលដើម្បីធានាថាល្បែងទាំងនោះមានលក្ខណៈយុត្តិធម៌។ គ្មាន 'ល្បែងល្អបំផុត' សម្រាប់លេងទេ។ ល្បែងខ្លះមានរង្វាន់ធំៗណាស់ដែលពិបាកឈ្នះមែនទែន ខណៈដែល Draw Lotteries និង Instant Lotteries ផ្ដល់ឱកាសឱ្យអ្នកឈ្នះរង្វាន់តូចៗកាន់តែច្រើន។

បើសិនអ្នកចង់និយាយជាមួយនរណាម្នាក់នៅថ្ងៃនេះដើម្បីស្វែងរកព័ត៌មាន និងការគាំទ្រ សូមហៅទូរសព្ទទៅ

**GambleAware**
gambleaware.nsw.gov.au
1800 858 858

GambleAware នៅបម្រើអ្នកគ្រប់ពេល 24ម៉ោងក្នុងមួយថ្ងៃ 365ថ្ងៃក្នុងមួយឆ្នាំ។

អ្នកអាចរកជំនួយដោយសម្ងាត់ និងមិនគិតថ្លៃ។

អ្នកអាចនិយាយជាមួយនរណាម្នាក់ជាភាសារបស់អ្នកបាន។ យើងមានអ្នកផ្តល់ប្រឹក្សាដែលនិយាយភាសាផ្សេងពីភាសាអង់គ្លេស ហើយអ្នកបកប្រែផ្ទាល់មាត់សម្រាប់ជួយអ្នក។

យើងផ្តល់ការគាំទ្រដល់អ្នកលេងល្បែងស៊ីសង – ហើយនិងក្រុមគ្រួសារ និងមិត្តភក្តិរបស់ពួកគេ។

បោះពុម្ពដោយ
The Office of Responsible Gambling
GPO Box 7060, Sydney NSW 2001

www.responsiblegambling.nsw.gov.au

សម្រាប់ច្បាប់ចម្លងជាច្រើនច្បាប់នៃបណ្ណព័ត៌មាននេះ៖
1]អ៊ីម៉េល៖ contact.us@liquorandgaming.nsw.gov.au
ទូរសព្ទ៖ 1300 024 720

NSW GOVERNMENT

ខែធ្នូ ឆ្នាំ2020 | KHMER

# ព័ត៌មានអំពីឱកាសរបស់អ្នក

## ការភ្នាល់លើល្បែងតាមតុនៅកាស៊ីណូ



**GambleAware**
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

ល្បែងឱកាស ឬជំនាញនៅកាស៊ីណូអាចមានលក្ខណៈជក់ចិត្តសម្រាប់មនុស្សដែលចូលចិត្តភ្នាល់លើការបង្វិលកង់រង្វង់ ការចែកសន្លឹកបៀ និងប្រមៀលគ្រាប់ឡុកឡាក់។

ប៉ុន្តែកាស៊ីណូ បើកនៅទីនោះដើម្បីរកប្រាក់ចំណេញ។ ល្បែងនីមួយៗមានភាគរយឈ្នះដែលរក្សាទុកដោយបនល្បែង។ នេះគឺជាភាគរយទូទៅនៃប្រាក់ដែលបានភ្នាល់ ដែលដកទុកដោយកាស៊ីណូ គេក៏ស្គាល់ថា ជាបនល្បែង (the house)។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែងកាន់តែទាប ភាគនៃលុយដែលត្រូវ សងទៅអ្នកលេងកាន់តែខ្ពស់។

អ្នកលេងល្បែងជំនាញអាចកាត់បន្ថយភាគរយឈ្នះដែលរក្សាទុកដោយបនល្បែងជំនាញបាន ប៉ុន្តែភាគរយឈ្នះដែល រក្សាទុកដោយបនល្បែងនេះ មិនអាចផ្លាស់ប្តូរបានទេ ចំពោះល្បែងដែលផ្សងលើឱកាស(សំណាង) មិនថាមានយុទ្ធសាស្ត្រភ្នាល់បែបណានោះទេ។

ក្នុងរយៈពេលវែង អ្នកលេងភាគច្រើនមិនទំនងជានឹងឈ្នះទេ។ ល្បែងនីមួយៗត្រូវតែលេងទៅតាមបទដ្ឋានដែលអនុញ្ញាតដោយអាជ្ញាធរល្បែងស៊ីសង និងគ្រឿងស្រវឹងឯករាជ្យ។

## តើលេខរបស់អ្នកចេញញឹកញាប់ប៉ុណ្ណា?

### ល្បែងបៀអូសយ៉ិត (Blackjack)

Blackjack គឺជាល្បែងឱកាសតាមសន្លឹកបៀ និងជំនាញនៅក្នុងនោះ ដែលអ្នកលេងអាចបង្កើនឱកាសឈ្នះរបស់ពួកគេដោយប្រើយុទ្ធសាស្ត្រល្អជាង។ បន្ទាប់ពីទទួលសន្លឹកបៀពីរសន្លឹកពីអ្នកចែកហើយ អ្នកលេងជ្រើសអូសសន្លឹកបៀបន្ថែម ដើម្បីចំនួនគ្រាប់សរុប ខិតជិតដល់ 21គ្រាប់ ជាងគ្រាប់សរុបរបស់អ្នកចែកបៀ – ដោយមិនឱ្យលើសពី 21 គ្រាប់ទេ។ សន្លឹកបៀមានរូបមនុស្ស (រូបភាព) រាប់ថា 10គ្រាប់ អាត់រាប់ថា 1គ្រាប់ឬ11 គ្រាប់ ហើយសន្លឹកបៀ 1 ដល់ 10 រាប់ទៅតាមចំនួនគ្រាប់នៅលើសន្លឹកបៀ។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែងសម្រាប់ បៀBlackjackនេះ គឺជាទូទៅតិចជាង 1ភាគរយ សម្រាប់អ្នកលេងជំនាញ។

### ល្បែងបៀការីបៀនស្ពាត់ផូកឃ័រ (Caribbean Stud Poker)

ល្បែងសន្លឹកបៀនេះគឺល្បែងឱកាស និងជំនាញ ហើយផ្អែកលើផូកឃ័រមេចំនួនប្រាំសន្លឹក។ សម្រាប់ ‘ប្រាក់ភ្នាល់’ ឬ ‘ប្រាក់ចាក់’ ដំបូង អ្នកលេងទទួលបានសន្លឹកបៀប្រាំសន្លឹកផ្កាប់ ខណៈដែលអ្នកចែកទទួលសន្លឹកបៀបួនសន្លឹកផ្កាប់ និងមួយសន្លឹកផ្ងារ។ បើសិនអ្នកលេងគិតថាពួកគេមិនអាចឈ្នះបៀក្នុងដៃអ្នកចែកបានទេ ពួកគេអាចសុខចិត្តចាញ់ប្រាក់ភ្នាល់របស់ពួកគេ។ ដើម្បីលេងបន្ត ការភ្នាល់បន្ទាប់របស់អ្នកលេង ត្រូវតែដាក់ពីរដងនៃប្រាក់ភ្នាល់ដើមដំបូង។ ឈុតសន្លឹកបៀផូកឃ័រដែលល្អជាងគេបំផុត ក្នុងចំណោមអ្នកលេងនីមួយៗ និងអ្នកចែកសន្លឹកបៀ គឺជាអ្នកឈ្នះ។ ក៏មានការភ្នាល់យករង្វាន់ធំដែរ។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែង សម្រាប់ Caribbean Stud Poker គឺប្រហែលជា 5,5 ភាគរយ ដែលរាប់បញ្ចូលទាំងប្រាក់ទុកសម្រាប់រង្វាន់ធំ។

### ល្បែងបាការ៉ាត (Baccarat)

Baccarat គឺជាល្បែងឱកាសដែលសន្លឹកបៀមានលេខតិចជាង 10 រាប់យកតាមចំនួនគ្រាប់ដែលមានលើសន្លឹកបៀ អាត់មានតម្លៃស្មើនឹង 1 ហើយសន្លឹក 10 និងសន្លឹកបៀមានរូប (រូបភាព) មានតម្លៃស្មើនឹង 0។ សន្លឹកបៀពីរសន្លឹកចែកដល់ដៃអ្នកលេង និងអ្នកចែក បន្ទាប់មកដោយអាស្រ័យលើចំនួនសរុបនៃសន្លឹកបៀចំនួនពីរដំបូង សន្លឹកទីបីអាចហូតយកបាន។ ចំនួនសរុបទាំងនេះត្រូវបានអានដូចជាគ្មានលេខទីមួយនៅខាងមុខអញ្ចឹង – ដូច្នេះសន្លឹកបៀសរុបនៅក្នុងដៃ មាន15 គ្រាប់ ក្លាយជា 5គ្រាប់។ អ្នកឈ្នះល្បែងនេះ គឺជាអ្នកមានតម្លៃសន្លឹកបៀសរុបខិតទៅជិត 9គ្រាប់ជាងគេ។ អ្នកលេងអាចភ្នាល់លើសន្លឹកបៀក្នុងដៃអ្នកលេង ឬអ្នកចែក ឬភ្នាល់ថាឈុតសន្លឹកបៀនឹងមានគ្រាប់ស្មើគ្នា។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែង សម្រាប់ Baccarat គឺអំពី 1,2ភាគរយ។

### ល្បែងស៊ីកបូ (Sic Bo)

នៅក្នុង Sic Bo គ្រាប់ឡុកឡាក់ចំនួនបីគ្រាប់ត្រូវបានបង្វិល ហើយអ្នកលេងព្យាយាមទាយបន្សំចំនួនសរុប និងលទ្ធផលផ្សេងៗ។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែង សម្រាប់ប្រភេទភ្នាល់នីមួយៗខុសៗគ្នាពី 2,8 ភាគរយ (ធំ តូច ឬបន្សំនៃគ្រាប់ឡុកឡាក់ចំនួនពីរ) ដល់ 16,2 ភាគរយសម្រាប់ការត្រូវលេខបង្វិលដូចគ្នាបីដង។ Sic Bo គឺជាល្បែងឱកាស ដូច្នេះគ្មានយុទ្ធសាស្ត្រភ្នាល់ណា ដើម្បីបន្ថយភាគរយទាំងនេះបានទេ។

### ល្បែងក្រាបស៍ (Craps)

Craps គឺជាល្បែងដែលលេងជាមួយគ្រាប់ឡុកឡាក់ចំនួនពីរគ្រាប់ ដែលអ្នកលេងអាចភ្នាល់លើបន្សំណាមួយនៃគ្រាប់ឡុកឡាក់ទាំងពីរគ្រាប់នេះ។ អ្នកលេងទទួលបានឱកាសប្រមៀលគ្រាប់ឡុកឡាក់ដែលបានផ្តល់ឱ្យ ពួកគេភ្នាល់នៅលើខ្សែឈ្នះ ឬខ្សែមិនឈ្នះ។ ដោយប្រាំពីរគ្រាប់គឺជាបន្សំទូទៅជាងគេបង្អស់ អ្នកភ្នាល់ភាគច្រើនផ្អែកទៅលើអ្នកបោះគ្រាប់ឡុកឡាក់ដែលរមៀលចេញចំនួនប្រាំពីរគ្រាប់ ឬមិនរមៀលចេញចំនួនប្រាំពីរគ្រាប់។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែងទៅលើ Craps ខុសៗគ្នាច្រើនពី 16,67 ភាគរយ សម្រាប់ការភ្នាល់លើចំនួនប្រាំពីរគ្រាប់ណាមួយ (រមៀលម្តង) ដល់ 0,85 ភាគរយទៅលើក្តីសង្ឃឹមឈ្នះ។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែងគឺប្រហែល 2 ភាគរយ។

### ល្បែងរ៉ូឡែត និងរ៉ូឡែតលេខសូន្យឌុប (Roulette and Double Zero Roulette)

ល្បែងឱកាស កង់រ៉ូឡែតអូស្ត្រាលីមានលេខចំនួន 37 នៅលើវា៖ 18 ក្រហម 18 ខ្មៅ និងសូន្យមួយ ឬនៅក្នុងករណីរ៉ូឡែតសូន្យឌុបមាន 38 លេខ។ កង់ត្រូវបានបង្វិលក្នុងទិសដៅមួយ ហើយកូនបាល់មិនមែនគ្រាប់ដែកតូចមួយនៅក្នុងទិសដៅផ្សេង។ អ្នកលេងអាចភ្នាល់លើលេខតែមួយ (Straight Up) (ការភ្នាល់កូនបាល់ធ្លាក់ចូលលេខជាក់លាក់មួយ) ឬក៏ភ្នាល់លើបន្សំលេខក្រហម ឬខ្មៅ លេខសេស ឬគូ ហើយទាប ឬខ្ពស់ (ថាតើលេខនៅចន្លោះ 1 និង 18 ឬ 19 និង 36 រួមគ្នា)។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែងគឺ 2,7 ភាគរយ សម្រាប់រ៉ូឡែត និង 5,26 ភាគរយសម្រាប់រ៉ូឡែតលេខសូន្យឌុប។

### ល្បែងប៉ៃហ្គៅ (Pai Gow)

ល្បែងឱកាសមួយទៀត Pai Gow បកប្រែមកថាធ្វើឱ្យបានលេខប្រាំបួន។ Pai Gow គឺលេងដោយមានគ្រាប់ដូមីណូចំនួន 32។ គ្រាប់ដូមីណូចំនួនម្ភៃពីរនៃគ្រាប់ទាំងនេះបង្កើតបាន 11 គូដូចគ្នា និង10 គ្រាប់ទៀតបង្កើតបានប្រាំគូលាយគ្នា។ បន្ទាប់ល្បែងបានចែក អ្នកលេងនីមួយៗ និងអ្នកភ្នាល់ (the Bank) (ឬបនល្បែង-the house) ត្រូវការកសាងឈុតដាច់ពីគ្នាចំនួនពីរ ដោយប្រើគ្រាប់ដូមីណូចំនួនបួនគ្រាប់ដែលគេហៅថា ឈុតទាប (Low Hand) និងឈុតខ្ពស់ (High Hand)។ ឈុតនៅក្នុងដៃរបស់អ្នកលេង និងឈុតនៅក្នុងដៃរបស់ the Bank បន្ទាប់មកត្រូវប្រៀបធៀបដើម្បីកំណត់ថាអ្នកណាឈ្នះ។ ភាគរយឈ្នះដែលរក្សាទុកដោយបនល្បែងសម្រាប់ Pai Gow គឺ 1,5 ភាគរយ។

## តើអ្នកអាចបង្កើនក្តីសង្ឃឹមរបស់អ្នកបានទេ?

មិនបានទេ – មិននៅក្នុងល្បែងឱកាសទេ – ពីព្រោះគ្រាប់ឡុកឡាក់ និងកង់វិលគ្មានការចងចាំទេ។ នៅក្នុងល្បែងឱកាស ភាគរយឈ្នះរក្សាទុកដោយបនល្បែងគឺកំណត់ដោយបទដ្ឋាន។



បើសិនអ្នកចង់និយាយជាមួយនរណាម្នាក់នៅថ្ងៃនេះដើម្បីស្វែងរកព័ត៌មាន និងការគាំទ្រ សូមហៅទូរសព្ទទៅ

**GambleAware**
gambleaware.nsw.gov.au
1800 858 858

GambleAware នៅបម្រើអ្នកគ្រប់ពេល 24ម៉ោងក្នុងមួយថ្ងៃ 365ថ្ងៃក្នុងមួយឆ្នាំ។

អ្នកអាចរកជំនួយដោយសម្ងាត់ និងមិនគិតថ្លៃ។

អ្នកអាចនិយាយជាមួយនរណាម្នាក់ជាភាសារបស់អ្នកបាន។ យើងមានអ្នកផ្តល់ប្រឹក្សាដែលនិយាយភាសាផ្សេងពីភាសាអង់គ្លេស ហើយអ្នកបកប្រែផ្ទាល់មាត់សម្រាប់ជួយអ្នក។

យើងផ្តល់ការគាំទ្រដល់អ្នកលេងល្បែងស៊ីសង – ហើយនិងក្រុមគ្រួសារ ព្រមទាំងមិត្តភក្តិរបស់ពួកគេ។


បោះពុម្ពដោយ
The Office of Responsible Gambling
GPO Box 7060, Sydney NSW 2001

www.responsiblegambling.nsw.gov.au

សម្រាប់ច្បាប់ចម្លងជាច្រើនច្បាប់នៃបណ្ណព័ត៌មាននេះ៖ 1]អ៊ីម៉េល៖ contact.us@liquorandgaming.nsw.gov.au
ទូរសព្ទ៖ 1300 024 720


# ជំនួយនៅជិតបង្កើយ

## នៅទីនេះសម្រាប់អ្នក 24ម៉ោងក្នុងមួយសប្តាហ៍។



NSW GOVERNMENT


ខែសីហា ឆ្នាំ 2021 | ភាសាអង់គ្លេស
4-ភាសាអង់គ្លេស។ 0821។ LG34100


**GambleAware**
gambleaware.nsw.gov.au
1800 858 858

NSW GOVERNMENT

## តើការលេងល្បែងស៊ីសងពិតជាធ្វើឱ្យអ្នកខាតបង់អស់ប៉ុន្មាន?

មនុស្សភាគច្រើនលេងល្បែងស៊ីសងម្តងម្កាល។ វាអាចជាការចុចម៉ាស៊ីនផូកឃ័រ លេងនៅ TAB ទិញសន្លឹកឆ្នោត ឬលេងនៅកាស៊ីណូ។ សម្រាប់មនុស្សជាច្រើន ការលេងល្បែងស៊ីសងគឺសប្បាយ ជក់ចិត្ត ហើយមិនបង្កគ្រោះអាក្រក់អ្វីទេ។

ប៉ុន្តែ សម្រាប់មនុស្សខ្លះ ការលេងល្បែងស៊ីសងអាចក្លាយជាបញ្ហា។ ការលេងល្បែងស៊ីសងអាចធ្វើឱ្យខាតបង់ខ្ពស់ - ទាំងផ្នែកហិរញ្ញវត្ថុ ផ្លូវចិត្ត និងផ្ទាល់ខ្លួន។ ការលេងល្បែងស៊ីសងអាចអន្តរាយសម្រាប់អ្នកលេងល្បែង ហើយនិងក្រុមគ្រួសារ និងមិត្តភក្តិរបស់ពួកគេ។





## តើខ្ញុំដឹងថាការលេងល្បែងស៊ីសងបង្កជាបញ្ហាដោយរបៀបណា?

បើសិនការលេងល្បែងស៊ីសងកំពុងបង្កឱ្យមានស្រេស្ត ឬមួម៉ៅ វាអាចជាសញ្ញានៃបញ្ហា។ សញ្ញាផ្សេងទៀតដែលការលេងល្បែងស៊ីសងកំពុងបង្កគ្រោះអាក្រក់ គឺ៖

- ការមានអារម្មណ៍ថាមានកំហុស មួម៉ៅ ឬបាក់ទឹកចិត្ត  អំពីការលេងល្បែងស៊ីសង
- បាត់បង់ការគ្រប់គ្រងលើការចំណាយពេលវេលា និងប្រាក់កាសទៅលើការលេងល្បែងស៊ីសង
- ការដកខ្លួនចេញពីគ្រួសារ និងមិត្តភក្តិ
- ការព្យាយាមឈ្នះលុយដែលចាញ់មកវិញ ដោយបន្តលេងល្បែងស៊ីសងបន្តទៀត
- ការខ្ចីលុយ ឬលក់របស់របរមានតម្លៃដើម្បីលេងល្បែងស៊ីសង
- ការខកខានមិនបង់វិក្កយបត្រទាន់ពេល ឬចុះកុងត្រាប្រើកាតឥណទានថ្មី
- ការគិតអំពីការលេងល្បែងស៊ីសងរាល់ថ្ងៃ
- ការនិយាយភូតភរអំពីការលេងល្បែងស៊ីសង

បើសិនអ្នក ឬនរណាម្នាក់កំពុងមានសញ្ញាណាមួយក្នុងចំណោមសញ្ញាទាំងនេះ វាជាការសំខាន់ដែលត្រូវទាក់ទងស្វែងរកព័ត៌មាន និងការគាំទ្រ។ អ្នកអាចទាក់ទង GambleAware ជាសេវាមិនគិតថ្លៃ និងដោយសម្ងាត់សម្រាប់មនុស្សដែលលេងល្បែងស៊ីសង ហើយគ្រួសារ និងមិត្តភក្តិរបស់ពួកគេ។

វាមិនយឺតពេលពេកទេក្នុងការទទួលជំនួយ – អ្នកអាចទាក់ទងមកយើងនៅថ្ងៃនេះ។

## ជំនួយនៅជិតបង្កើយ

អ្នកអាចទទួលព័ត៌មាន និងការគាំទ្រដោយទាក់ទង GambleAware។

GambleAware មានសេវាទូរសព្ទសម្ងាត់ដែលផ្តល់ព័ត៌មាន ការគាំទ្រ និងការបញ្ជូនទៅកាន់សេវាផ្សេងៗទៀត។ សេវាយើងមានគ្រប់ពេលវេលា៖ 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ វាជាការហៅទូរសព្ទដោយមិនគិតថ្លៃ – ជាការពិត លេខទូរសព្ទយើងមិនបង្ហាញនៅលើវិក្កយបត្ររបស់អ្នកទេ។

បើសិនអ្នកចង់សរសេរជាអក្សរជាជាងការនិយាយនោះ អញ្ចឹងអាចជជែកគ្នាបាន 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍នៅ www.gamblinghelponline.org.au។

ក៏មានសេវាផ្តល់ប្រឹក្សានានារបស់ GambleAware ផងដែរ នៅទូទាំងរដ្ឋញូសៅវ៉េល។ ដើម្បីស្វែងរកសេវាកម្មមួយនៅក្បែរអ្នក ចូរហៅទូរសព្ទទៅលេខ 1800 858 858 ឬរកមើលសេវាក្នុងតំបន់អ្នកនៅលើ www.gambleaware.nsw.gov.au/i-need-support។

មានសេវាគាំទ្រឯកទេសសម្រាប់ស្ត្រី អ្នកដែលមានអត្តសញ្ញាណជាជនជាតិដើមអាបូរីជីណល និងអ្នកកោះធ័ររេស្រ្តេត (Torres Strait) និងសម្រាប់អ្នកដែលនិយាយភាសាផ្សេងក្រៅពីភាសាអង់គ្លេស។

ជំនួយផ្នែកច្បាប់ និងហិរញ្ញវត្ថុក៏មានសម្រាប់អ្នក បើសិនអ្នកកំពុងជួបបញ្ហាប្រឈមផ្នែកច្បាប់ ឬហិរញ្ញវត្ថុ ដោយសារការលេងល្បែងស៊ីសង។

បើសិនអ្នកមិនទាន់ត្រៀមខ្លួនរួចរាល់ដើម្បីនិយាយជាមួយអ្នកផ្តល់ប្រឹក្សាទេ មានជម្រើសជាច្រើនដូចជា ការដកខ្លួនចេញពីកន្លែងលេងល្បែងស៊ីសង ឬការលេងតាមអនឡាញ ដោយខ្លួនឯង ធនធានដែលជួយដោយខ្លួនឯងតាមអនឡាញនៅវ៉ិបសាយថ៍របស់ GambleAware និងផ្នែកពិសេសសម្រាប់គ្រួសារ និងមិត្តភក្តិដែលបង្ហាញពីសកម្មភាពងាយៗ ដែលអ្នកអ្នកធ្វើបាន បើសិនអ្នកបារម្ភអំពីមនុស្សដែលអ្នកស្រលាញ់។

**សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីទទួលការគាំទ្រនៅថ្ងៃនេះ ហៅទូរសព្ទទៅកាន់លេខ 1800 858 858 ឬចូលមើល gambleaware.nsw.gov.au**